**សេចក្តីថ្លែងការណ៍រួម**
**រដ្ឋាភិបាលបង្កើនការរឹតត្បិតលើគេហទំព័រសារព័ត៌មានសំខាន់ៗមុនការបោះឆ្នោតថ្នាក់ជាតិ**

**ភ្នំពេញ, ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ ២០២៣**- យើងខ្ញុំ ដែលជាស្ថាប័នដូចមានរាយនាមខាងក្រោម បង្ហាញការព្រួយបារម្ភជុំវិញការសម្រេចចិត្តរបស់រដ្ឋាភិបាលក្នុងការបិទខ្ទប់គេហទំព័រព័ត៌មានមួយចំនួននៅមុនការបោះឆ្នោតជាតិ ដែលជាការរំលោភបំពានធ្ងន់ធ្ងរលើសិទ្ធិទទួលបានព័ត៌មានរបស់ប្រជាពលរដ្ឋ។

កាលពីសប្តាហ៍មុន ក្រសួងព័ត៌មានបានបញ្ជាឱ្យនិយតករទូរគមនាគមន៍កម្ពុជាបិទគេហទំព័រ ទំព័របណ្តាញសង្គមរបស់ប្រព័ន្ធផ្សព្វផ្សាយមួយចំនួន និងគេហទំព័រទិន្នន័យសាធារណៈ ដែលទើបដាក់ឱ្យដំណើរការដោយនាយកប្រតិបត្តិនៃមជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ(CCIM) ។ ការសម្រេចចិត្តនេះជាការប៉ុនប៉ងរាំងពលរដ្ឋមិនឱ្យចូលមើលព័ត៌មាន ពីគេហទំព័រ និង ទំព័របណ្តាញសង្គម ដែលផ្សាយពីការរិះគន់រដ្ឋាភិបាល។

ការរាំងខ្ទប់គេហទំព័រព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយបណ្តាញសង្គមពីសំណាក់ក្រសួងព័ត៌មាន បានរឹតត្បឹតដល់ពលរដ្ឋពីការចូលទៅគេហទំព័រ និងបណ្តាញសង្គមរបស់ ឌឹខេមបូឌាដេលី វិទ្យុអាស៊ីសេរី និងគេហទំព័រទិន្នន័យសាធារណៈឈ្មោះថា «កំណត់ត្រា» ដែលគ្រប់គ្រងដោយមជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ។

ក្នុងដំណើរឆ្ពោះទៅរកការបោះឆ្នោតជាតិ ដែលនឹងធ្វើឡើងនៅថ្ងៃអាទិត្យ ទី២៣ ខែកក្កដា ឆ្នាំ២០២៣ យើងបានមើលឃើញពីការគាបសង្កត់សិទ្ធិពលរដ្ឋ ពិសេសសិទ្ធិទទួលបានព័ត៌មាន។

លោក អ៊ិត សូធឿត នាយកប្រតិបត្តិនៃមជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ( CCIM ) បានឲ្យដឹងថា៖ «ព័ត៌មាន មានសារៈសំខាន់ណាស់សម្រាប់ប្រជាពលរដ្ឋនៅក្នុងសង្គមប្រជាធិបតេយ្យ ដើម្បីធ្វើការសម្រេចចិត្តប្រកបដោយការយល់ដឹង។ ការរាំងខ្ទប់គេហទំព័រទាំងនោះនឹងប៉ះពាល់ដល់សិទ្ធិពលរដ្ឋក្នុងការទទួលបានព័ត៌មាន ដែលត្រូវបានធានាដោយច្បាប់។ វាក៏បានបង្កផលប៉ះពាល់ដល់ការងាររបស់អ្នកសារព័ត៌មាន ដែលខិតខំធ្វើឱ្យអ្នករាល់គ្នាទទួលបានព័ត៌មានផងដែរ»។

ខណៈរដ្ឋាភិបាលអះអាងថា «កំណត់ត្រា» របស់ CCIM ដំណើរការជាសារព័ត៌មានដោយគ្មានអាជ្ញាប័ណ្ណប្រព័ន្ធផ្សព្វផ្សាយនោះ លោក សូធឿត បានឲ្យដឹងថា កំណត់ត្រា មិនមែនជាប្រព័ន្ធផ្សព្វផ្សាយទេ ប៉ុន្តែជាមូលដ្ឋានទិន្នន័យ ដែលចងក្រងឯកសារ ទិន្នន័យ និងព័ត៌មានរបស់រដ្ឋាភិបាល ដែលបានបោះពុម្ពរួច។

លោកបន្ថែមទៀតថា៖ «នៅក្នុងពេលដ៏សំខាន់មុនពេលបោះឆ្នោត ការទទួលបានព័ត៌មានគួរតែត្រូវបានលើកទឹកចិត្ត ហើយព័ត៌មានពីគ្រប់ភាគីទាំងអស់គួរតែត្រូវបានអនុញ្ញាត។ គោលដៅរបស់ **កំណត់ត្រា** គឺ ចងក្រង

កំណត់ត្រាសាធារណៈទាំងអស់ ហើយដាក់វាជាទម្រង់ងាយស្រួលសម្រាប់ប្រជាជនគ្រប់គ្នាចូលទៅប្រើប្រាស់ ហើយនេះគឺជាការខាតបង់ដ៏ធំមួយសម្រាប់ផលប្រយោជន៍សាធារណៈ ដែលគេហទំព័រនេះត្រូវបានបិទ»។

ប្រជាជនមានសិទ្ធិទទួលបានព័ត៌មានត្រឹមត្រូវពីប្រភពព័ត៌មានផ្សេងៗ ហើយរដ្ឋាភិបាលមានទំនួលខុសត្រូវក្នុងការធានាការទទួលបានព័ត៌មានទាំងនោះ។

វិធានការទាំងនេះក៏កើតមានឡើងបន្ទាប់ពីការសម្រេចចិត្តរបស់រដ្ឋាភិបាលក្នុងការបិទប្រព័ន្ធផ្សព្វផ្សាយឯករាជ្យដ៏ធំមួយនៅកម្ពុជាកាលពីខែ កុម្ភៈ គឺ សំឡេងប្រជាធិបតេយ្យ (VOD)។

លោក ណុប វី នាយកប្រតិបត្តិ ខេមបូចាថ្លែងថា ៖«ព័ត៌មានគឺកាន់តែមានសារៈសំខាន់ក្នុងអំឡុងពេល និងមុនពេលបោះឆ្នោតខាងមុខនេះ»។ ការហាមឃាត់ការទទួលបានព័ត៌មានចម្រុះអាចជះឥទ្ធិពលដល់សុចរិតភាពនៃការបោះឆ្នោត និងសិទ្ធិរបស់អ្នកបោះឆ្នោតក្នុងការទទួលបានព័ត៌មាន។»

-

**សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង:**
**លោក ណុប វី នាយកប្រតិបត្តិខេមបូចា**
**ទូរស័ព្ទ: (+៨៥៥)១២ ៥១៩ ២៦១**
**អ៊ីម៉ែល:** ed@camboja.net

__ស្ថាប័នក្នុងស្រុក និងថ្នាក់តំបន់ ដែលគាំទ្រនៅក្នុងសេចក្ដីថ្លែងការណ៍នេះ:__

១. សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (CamboJA)
២. មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM)
៣. សហព័ន្ធអ្នកសារព័ត៌មានអន្តរជាតិ (IFJ)
៤. សហជីពជាតិអ្នកសារព័ត៌មាននៃប្រទេសហ្វីលីពីន (NUJP)
៥. Overseas Press Club of Cambodia (OPCC)
៦. សមាគមអ្នកសារព័ត៌មានទីម័រ (Association Journalist Timor Leste)
៧.សម្ព័ន្ធអ្នកសារព័ត៌មានឯករាជ្យឥណ្ឌូនេស៊ី The Alliance of Independent Journalists (Indonesia)